# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ១៣

LECTURE 13

## សមត្ថកិច្ចរដ្ឋ

COMPETENCY OF STATES

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្តីផ្តើម
- ផ្នែកទី២ សមត្ថកិច្ចដែនដី
  - សញ្ញាណទូទៅ
  - សមត្ថកិច្ចទូទៅ
  - សមត្ថកិច្ចផ្តាច់មុខ
- ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល
  - សញ្ញាណទូទៅ
  - រូបវន្តបុគ្គល
  - នីតិបុគ្គល
  - យានយន្ត

# កម្មវត្ថុនៃមេរៀន

នៅក្នុងមេរៀនស្ដីពីសមត្ថកិច្ចរដ្ឋ មានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពី៖

- សមត្ថកិច្ចរបស់រដ្ឋចំពោះពលរដ្ឋរបស់ខ្លួន
- សមត្ថកិច្ចទូទៅ និងសមត្ថកិច្ចផ្ដាច់មុខរបស់រដ្ឋ
- ការចុះបញ្ជីយានយន្តដែលធ្វើចរាចរក្នុងដែនអន្តរជាតិ
- លក្ខខណ្ឌក្នុងការទទួលបានសញ្ជាតិរបស់រូបវន្តបុគ្គល និងនីតិបុគ្គល

# ផ្នែកទី១ សេចក្តីផ្តើម

សមត្ថកិច្ចរដ្ឋ ជាអំណាចដែលផ្តល់ឲ្យរដ្ឋអាចធ្វើអ្វីៗបាន ឬចាត់ចែងកិច្ចការទាំងឡាយ នៅក្នុងវង្វង់សមត្ថកិច្ចដែនដីរបស់ខ្លួន ចំពោះប្រជាជនដែលស្ថិតនៅក្នុងទឹកដីខ្លួន។ ក្នុងក្របខ័ណ្ឌនៃច្បាប់អន្តរជាតិ រដ្ឋមិនមែនមានតែសម័ត្ថកិច្ចក្នុងដែនដីរបស់ខ្លួនទេ ក៏អាចមានសមត្ថកិច្ចក្រៅដែនដីដែរ។

# ផ្នែកទី១ សេចក្តីផ្តើម

ជាទូទៅ រដ្ឋមានសមត្ថកិច្ចពីរយ៉ាងគឺ សមត្ថកិច្ចដែនដី និង សមត្ថកិច្ចបាតិបុគ្គល។ នៅក្នុងផ្នែកទី២នៃមេរៀនេះ នឹងនិយាយពីសមត្ថកិច្ចដែនដី ហើយនៅក្នុងផ្នែកទី៣ នឹងនិយាយពីសមត្ថកិច្ចបាតិបុគ្គល។

# ផ្នែកទី១ សេចក្ដីផ្ដើម

សមត្ថកិច្ចដែនដី ត្រូវបានបែងចែកជាអំណាចដែលរដ្ឋអនុវត្តក្នុងដែនដីរបស់ខ្លួនផង និងសមត្ថកិច្ចដែលអនុវត្តនៅក្រៅដែនដីរបស់ខ្លួនផង។ នៅក្នុងមេរៀននេះ យើងនឹងមិនធ្វើការសិក្សាពីសមត្ថកិច្ចក្រៅដែនដីរបស់រដ្ឋនោះឡើយ ក៏ដោយសារតែសមត្ថកិច្ចក្រៅដែនដីមានលក្ខណៈទូលំទូលាយ។

# ផ្នែកទី១ សេចក្ដីផ្ដើម

ប្រសិនបើយើងនិយាយពី សមត្ថកិច្ចបាតិបុគ្គលរបស់រដ្ឋវិញ គឺសំដៅទៅដល់ អំណាដែលរដ្ឋត្រូវអនុវត្តចំពោះពលរដ្ឋរបស់ខ្លួន និងចំពោះទ្រព្យសម្បត្តិរបស័រដ្ឋ (ទ្រព្យសាធារណៈរបស់រ័ដ្ឋ និងទ្រព្យឯកជនរបស់រដ្ឋ) ផងដែរ និងទ្រព្យសម្បត្តិឯកជន។

# ផ្នែកទី២ សមត្ថកិច្ចដែនដី

- សញ្ញាណទូទៅ

ដែនដីគឺជាអ្នកកំណត់នូវសមត្ថកិច្ចរបស់រដ្ឋ ប្រសិនបើដែនដីរបស់រដ្ឋទៅដល់ទីណា សមត្ថកិច្ចរបស់រដ្ឋក៏ទៅដល់ទីនោះដែរ ឬ គេអាចនិយាយបានថា ទឹកដីណាជាកម្មសិទ្ធិរបស់រដ្ឋណាមួយ រដ្ឋនោះមានសមត្ថកិច្ចនៅទីនោះដែរ។

# ផ្នែកទី២ សមត្ថកិច្ចដែនដី

- សញ្ញាណទូទៅ

នៅក្នុងក្របខ័ណ្ឌនៃនីតិអន្តរជាតិ បានផ្តល់នូវសារៈសំខាន់ដ៏មហិមាចំពោះគោលការណ៍ការមិនកែប្រែព្រំដែនរបស់រដ្ឋ ក៏ព្រោះតែបើមានការកែប្រែព្រំដែនរបស់រដ្ឋ វាក៏នាំឲ្យមានការកែប្រែនូវសមត្ថកិច្ចរបស់រដ្ឋដែរ។

# ផ្នែកទី២ សមត្ថកិច្ចដែនដី

• សញ្ញាណទូទៅ

ការគោរពនូវអធិបតេយ្យ ក៏មានគោលបំណងដើម្បីធានាពីការអនុវត្តនូវសមត្ថកិច្ចរដ្ឋហួសដែនដីដែលរដ្ឋនោះមានផងដែរ។ គឺនៅលើដែនដីជាកំណត់នេះហើយ ដែលរដ្ឋនីមួយៗមានសមត្ថទូទៅផង និងសមត្ថកិច្ចផ្ដាច់មុខផង។

# ផ្នែកទី២ សមត្ថកិច្ចដែនដី

- សមត្ថកិច្ចទូទៅ

សមត្ថកិច្ចទូទៅរបស់រដ្ឋ បានផ្តល់ឲ្យរដ្ឋនូវដែនអនុវត្តមួយយ៉ាងទូលំទូលាយ ដែលគ្មានដែនកំណត់ និងគ្មានទីបញ្ចប់នៅក្នុងលំហ នោះប្រសិនបើគ្មានខ្សែបន្ទាត់ព្រំដែនជាអ្នកកំណត់ឲ្យវានោះឡើយ។

# ផ្នែកទី២ សមត្ថកិច្ចដែនដី

- សមត្ថកិច្ចទូទៅ

រដ្ឋនីមួយៗ មានសមត្ថកិច្ចគ្រប់គ្រាន់ និង ដោយពេញលេញ ក្នុងរៀបចំចាត់ចែងគ្រប់គ្រងនូវអំណាចរបស់ខ្លួនទាំងមូល នៅក្នុងដែនដីដែលជារបស់ខ្លួន ពោលដែលគេហៅថា ជាសមត្ថភាពក្នុងការគ្រប់គ្រងរដ្ឋ។

# ផ្នែកទី២ សមត្ថកិច្ចដែនដី

- សមត្ថកិច្ចទូទៅ

ទន្ទឹមនិងគ្នានេះផងដែរ រដ្ឋអាចរៀបចំតាក់តែងនូវបទដ្ឋានទាំងឡាយ ដែលចាត់ចែងពីការគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គល (រូបវន្តបុគ្គល និងនីតិបុគ្គល) ទាំងឡាយដែលស្ថិតនៅក្នុងដែនដីរបស់រដ្ឋខ្លួន។

# ផ្នែកទី២ សមត្ថកិច្ចដែនដី

- សមត្ថកិច្ចទូទៅ

សមត្ថកិច្ចទូទៅរបស់រដ្ឋ ក៏មានទំនាក់ទំនងផងដែរជាមួយនឹងធនធានធម្មជាតិទាំងឡាយ ដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន (គោលការណ៍នៃអធិបតេយ្យអចិន្ត្រៃយ៍លើធនធានធម្មជាតិ។ គ្រប់សកម្មភាពទាំងអស់របស់រដ្ឋ រាប់ទាំងសកម្មភាពបន្ទាប់បន្សំ រហូតដល់សកម្មភាពចម្បងៗ។

# ផ្នែកទី២ សមត្ថកិច្ចដែនដី

- សមត្ថកិច្ចទូទៅ

រដ្ឋមានសេរីភាពពេញលេញក្នុងការរៀបចំ ឬ ជ្រើសរើសនូវរបបនយោបាយ ប្រព័ន្ធសេដ្ឋកិច្ច វប្បធម៌ សង្គម និងសេវាកម្មសាធារណៈផ្សេងៗ ទៅតាមការចង់បានរបស់ខ្លួន ឬទៅតាមការចង់បានរបស់ប្រជាជនរបស់ខ្លួន។

# ផ្នែកទី២ សមត្ថកិច្ចដែនដី

- សមត្ថកិច្ចផ្តាច់មុខ

មានតែរដ្ឋតែម្នាក់ឯងគត់ ជាអ្នកដែលមានសមត្ថកិច្ចលើទឹកដីរបស់ខ្លួន ដូច្នេះអ្នកដ៏ទៃទៀតមិនអាចមានសមត្ថកិច្ចនេះបានឡើយ ដែលជាហេតុនាំឲ្យមាននូវវិស័យបម្រុងទុកសម្រាប់រដ្ឋ ដែលរដ្ឋ ឬ អង្គការអន្តរជាតិទាំងឡាយមិនអាចជ្រៀតជ្រែកបាន។

# ផ្នែកទី២ សមត្ថកិច្ចដែនដី

- សមត្ថកិច្ចផ្តាច់មុខ

លក្ខណៈផ្តាច់មុខនៃសមត្ថកិច្ចរដ្ឋនេះ គឺមានប្រភពដើមពីបទដ្ឋានទំនៀមទម្លាប់ ហើយវាត្រូវក្លាយទៅជាយុត្តិសាស្ត្រអន្តរជាតិ និងត្រូវបានគេយកមកប្រើប្រាស់ជាញឹកញាប់ ដូចក្នុងរឿងក្តីក័រហ្វ៉ូ ការគោរពអធិបតេយ្យដែនដីនៃរដ្ឋឯករាជ្យគឺជាមូលដ្ឋានជាសារវន្តក្នុងការធ្វើទំនាក់ទំនងអន្តរជាតិ។

# ផ្នែកទី២ សមត្ថកិច្ចដែនដី

- សមត្ថកិច្ចផ្តាច់មុខ

ដូចគ្នានេះផងដែរ មជ្ឈត្តវិនិច្ឆ័យអន្តរជាតិនៅក្នុងរឿងក្តីកោះប៉ាល់ម៉ាល ក៏បានលើកយកនូវលក្ខខណ្ឌនៃសមត្ថកិច្ចផ្តាច់មុខមកបញ្ជាក់ផងដែរ ពោលគឺរដ្ឋនីមួយៗមានសិទ្ធិអនុវត្តនូវតួនាទីជារដ្ឋក្នុងដែនដីរបស់ខ្លួន ដោយអនុញ្ញាតឲ្យមានការលូកដៃពីរដ្ឋដទៃទេ។

# ផ្នែកទី២ សមត្ថកិច្ចដែនដី

- សមត្ថកិច្ចផ្តាច់មុខ

សមត្ថកិច្ចនេះ ក៏ហាមប្រាមដល់រដ្ឋដ៏ទៃទៀតមិនឲ្យអនុវត្តនូវកិច្ចបង្ខំណាមួយមកលើរដ្ឋខ្លួន។ ឧទាហរណ៍ ប្រទេសអង់គ្លេសចូលទៅដោះមីននៅច្រកសមុទ្រប្រទេសអាល់បានីដោយពុំមានការអនុញ្ញាត ត្រូវបានតុលាការ ICJ ដាក់ទណ្ឌកម្ម។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- សញ្ញាណទូទៅ

សមត្ថកិច្ចបាតិបុគ្គល ជាអំណាចដែលអនុវត្តដោយរដ្ឋណាមួយទៅលើប្រជាពលរដ្ឋរបស់ខ្លួន ដែលកំពុងតែស្ថិតនៅក្នុងដែនដីរបស់ខ្លួន ឬ ដែលកំពុងតែស្នាក់នៅឯបរទេសផងដែរ សំខាន់ឲ្យតែជននោះនូវរក្សាចំណងបុគ្គលភាពគតិយុត្ត។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- សញ្ញាណទូទៅ

ការអនុវត្តនូវសមត្ថកិច្ចបាតិបុគ្គលរបស់រដ្ឋ គឺអាចអនុវត្តចំពោះ រូបវន្តបុគ្គល នីតិបុគ្គល ព្រមទាំងយានយន្តផងដែរ។ ដូច្នេះ ថាតើរដ្ឋអនុវត្តនូវសមត្ថកិច្ចបាតិបុគ្គលយ៉ាងណានោះ ក្នុងផ្នែកទី៣នេះនឹងធ្វើការបកស្រាយជូន។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- រូបវន្តបុគ្គល

សំដៅដល់បុគ្គលទាំងឡាយ ដែលស្ថិតនៅលើទឹកដីរបស់រដ្ឋណាមួយ គឺត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋនោះ ដោយរាប់ទាំងជនដែលមានសញ្ជាតិ និងដែលគ្មានសញ្ជាតិ។ ជនទាំងនោះត្រូវតែគោរពច្បាប់នៃរដ្ឋដែលខ្លួនកំពុងស្ថិតនៅ។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- រូបវន្តបុគ្គល

ប្រសិនបើយើងនិយាយពីសញ្ជាតិ គឺជាចំណងគតិយុត្តមួយ ដែលផ្សារភ្ជាប់បុគ្គលណាម្នាក់ទៅនឹងរដ្ឋណាមួយ។ ជាមួយគ្នានេះផងដែរ បុគ្គលអាចមានសញ្ជាតិរបស់រដ្ឋណាមួយបានដោយមិនគិតពីទីកន្លែងទេ។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- រូបវន្តបុគ្គល

រដ្ឋមានសមត្ថកិច្ចពេញលេញក្នុងការផ្តល់ ឬ មិនផ្តល់នូវសញ្ជាតិរបស់ខ្លួនទៅឲ្យបុគ្គលណាមួយ។ សមត្ថកិច្ចនេះ ក៏មានប្រភពដើមចេញពីបទដ្ឋានទំនៀមទម្លាប់ផងដែរ ហើយវាក៏ត្រូវបានទទួលស្គាល់ដោយយុត្តិសាស្ត្រទៀតផង។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- រូបវន្តបុគ្គល

សញ្ញាតិជាចំណងគតិយុត្ត ដែលមានមូលដ្ឋានលើហេតុការណ៍ ឬ ព្រឹត្តិការណ៍សង្គម ហើយដែលជាការផ្សាភ្ជាប់ចំណងសាមគ្គីភាពជាក់ស្តែង នៃផលប្រយោជន៍ខាងមនោសញ្ចេតនា ហើយក៏ជាការផ្សាភ្ជាប់នៃសិទ្ធិ និងកាតព្វកិច្ច។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- រូបវន្តបុគ្គល

រដ្ឋឯករាជ្យទាំងឡាយ មានសមត្ថកិច្ចពេលលេញក្នុងការកំណត់នូវវិធាន ក្នុងការធ្វើលទ្ធកម្មនៃសញ្ជាតិរបស់រូបវន្តបុគ្គល ដូចជារដ្ឋអាចធ្វើការផ្តល់សញ្ជាតិតាមសាច់ឈាម ឬតាមរយៈដើមកំណើត និងការផ្តល់សញ្ជាតិតាមរយៈទីកន្លែងកំណើត ជាអាទ៍។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- រូបវន្តបុគ្គល

សញ្ជាតិរបស់រូបវន្តបុគ្គល ក៏អាចនឹងទទួលបានផងដែរ តាមរយៈការធ្វើលទ្ធកម្ម (ការទទួលបាននូវសញ្ជាតិតាមរយៈអាពាហ៍ពិពាហ៍ តាមរយៈសុំកូន តាមរយៈជំនួយមនុស្សធម៌ ឬ អាចតាមរយៈការបោះទុនវិនិយោគ)។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- រូបវន្តបុគ្គល

ចូរចងចាំថា ទោះបីជារដ្ឋមានសិទ្ធិនេះដោយផ្ទាល់មុខក៏ដោយ ក៏រដ្ឋដាច់ខាតត្រូវតែគោរពនូវច្បាប់អន្តរជាតិផងដែរ។ សញ្ជាតិដែលជាចំណងចង់ភ្ជាប់រូបវន្តបុគ្គលទៅនឹងរដ្ឋណាមួយ ត្រូវតែជាចំណងពិតប្រាកដជាក់ស្តែង។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- រូបវន្តបុគ្គល

សេរីភាពក្នុងការកំណត់សញ្ជាតិរបស់រដ្ឋ អាចបង្ករឲ្យវិវាទសញ្ជាតិ ដែលជួនកាលវាគឺជាវិវាទវិជ្ជមាន (ពហុសញ្ជាតិ) និងជួលកាលទៀតគឺជាវិវាទអវិជ្ជមាន (គ្មានសញ្ជាតិ ឬ នីរេតិភាព)។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- នីតិបុគ្គល

រដ្ឋឆន្ទានុសិទ្ធិ ដើម្បីធ្វើការកំណត់ពីលក្ខខណ្ឌក្នុងការផ្តល់សញ្ជាតិសម្រាប់នីតិបុគ្គល ដែលជាក្រុមហ៊ុន ឬ អង្គការក្រៅរដ្ឋាភិបាលណាមួយទៅតាមបរិបទ និងអាស្រ័យទៅតាមច្បាប់របស់ខ្លួនដែលនៅជាធរមាន។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- នីតិបុគ្គល

លក្ខខណ្ឌវិនិច្ឆ័យ ដែលកំណត់សម្រាប់ការផ្តល់សញ្ជាតិដល់នីតិបុគ្គល ជាទូទៅគេពិនិត្យទៅលើ ការស្នាក់មេដែលនីតិបុគ្គលនោះតាំងនៅ ហើយគេក៏អាចធ្វើការពិនិត្យទៅលើស្ថានភាពជាក់ស្តែងរបស់នីតិបុគ្គលនោះផងដែរ។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- នីតិបុគ្គល

ការពិនិត្យទៅលើស្ថានភាពជាក់ស្តែរបស់នីតិបុគ្គល គឺគេត្រូវពិនិត្យមើលថា តើអ្នកណាជាប្រធានក្រុមហ៊ុន និងអ្នកណាខ្លះគឺជាម្ចាស់ភាគហ៊ុន ហើយដែលមានចំណែកភាគហ៊ុនច្រើនជាងគេ។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- នីតិបុគ្គល

ចំពោះករណី អង្គការក្រៅរដ្ឋាភិបាលវិញ គឺមិនសំខាន់លើបុគ្គលដែលបានស្នើសុំបើកអង្គការនោះទេ គឺគាត់អាចជាជនជាតិអ្វីក៏បាន។ សំខាន់តើគាត់មានការិយាល័យមេតាំងនៅកន្លែងណា។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- យានយន្ត

ជាទូទៅ យានយន្តមួយចំនួនដាច់ខាតត្រូវមានសញ្ជាតិដើម្បីអាចធ្វើចរាចរឆ្លងកាត់ដែនលំហាដែលមិនស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់រដ្ឋណាមួយ ដូចជាលំហាសមុទ្រអន្តរជាតិ ឬលំហាអាកាសអន្តរជាតិ ជាអាទិ៍។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- យានយន្ត

សូមគត់សម្គាល់ថា រដ្ឋមានសិទ្ធិផ្តាច់មុខក្នុងធ្វើការវាយប្រហារទៅលើនាវា ឬ យន្តហោះដែលគ្មានអត្តសញ្ញាណជូច្នេះហើយ យានយន្តទាំងនេះត្រូវមានសញ្ជាតិ ហើយមានតែមួយគត់ថែមទៀតផង។

# ផ្នែកទី៣ សមត្ថកិច្ចជាតិបុគ្គល

- យានយន្ត

សម្រាប់នាវាស៊ីវិល ជាធម្មតាគេអនុញ្ញាតឲ្យជ្រើសរើសនូវសញ្ជាតិរបស់រដ្ឋណាមួយដោយសេរី។ ម្ចាស់នាវាភាគច្រើនតែងតែធ្វើការជ្រើសរើសកន្លែងចុះបញ្ជី ដែលពុំសូវមានការត្រួតពិនិត្យតឹងតែងពេក។ នាវាបើចុះបញ្ជីនៅទៅណា គឺមានសញ្ជាតិនៃទីកន្លែងដែលបានចុះបញ្ជីនោះ។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- យានយន្ត

សម្រាប់យន្តហោះវិញ គឺវាក៏ត្រូវតែមានសញ្ជាតិតែមួយគត់ដូចទៅនឹងនាវាដែរ។ យន្តហោះ ដាច់ខាតត្រូវតែចុះលេខ បើទោះបីជាយានប្រភេទនេះ ភាគច្រើនអាស្រ័យក្រុមហ៊ុនពហុជាតិយ៉ាងណាក៏ដោយ។

# ផ្នែកទី៣ សមត្ថកិច្ចបាតិបុគ្គល

- យានយន្ត

ដូចគ្នាផងដែរសម្រាប់យន្តហោះ ការត្រួតពិនិត្យពុំមានបញ្ហាចោទឡើយ នេះក៏ដោយសារតែបើសិនពុំមានការធានាពីសន្តិសុខ សុវត្ថិភាពសម្រាប់អតិថិជនទេ វាធ្វើឲ្យបាត់បង់នូវសេចក្តីទុកចិត្ត។

មេរៀនទី១៣ ស្តីពីសមត្ថកិច្ចនៃរដ្ឋ ត្រូវបានបញ្ចប់។ សូមអរគុណសម្រាប់ការតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។